# ១៦

## អារម្មណ៍ ដែលត្រូវមាន មុនពេលស្លាប់[1]

*តាមព្រះពុទ្ធសាសនា កម្មអាចចែកជា ៤ប្រភេទ គឺ: ១- គរុកកម្ម (កម្មធ្ងន់)*
*២- អាសន្នកម្ម (កម្មជិតស្លាប់) ៣- អាចិណ្ណកម្ម (កម្មអចិន្ត្រៃយ៍ - ទម្លាប់)*
*៤- កដត្តាកម្ម (កម្មមិនជាក់លាក់) ។*

**១- គរុកកម្ម** *កម្មដែលមានទម្ងន់ធ្ងន់*

*ក/ ខាងកុសល គឺមានទម្ងន់ខ្លាំងក្លា ដែលមិនមានកម្មឯណានីមួយមកកាត់ផ្ដាច់ ឬជំនួសក្នុងការសម្រេច នៃជាតិបន្ទាប់។ ម្យ៉ាងវិញទៀត គរុកកម្មនេះ ច្បាស់ណាស់ថានឹងឲ្យផលតាក់តែងកំណើតថ្មីនៃជាតិខាងមុខ ។*

*ខ/ ខាងអកុសល គឺបាបកម្មដ៏ធ្ងន់ ៥ យ៉ាង (បញ្ចានន្តរិយកម្ម) ហើយនិងការយល់ខុសជាប្រចាំ (និយតមិច្ឆាទិដ្ឋិ)។*

***-អនន្តរិយកម្ម៥*** *មាន:* 1- *សម្លាប់បិតា* 2- *សម្លាប់មាតា* 3- *សម្លាប់ព្រះអរហន្ត*
4- *បង្ហូរឈាមព្រះពុទ្ធ* 5- *ញុះញង់បំបែកបំបាក់សង្ឃ ។*

***-និយតមិច្ឆាទិដ្ឋិ*** *គឺបុគ្គលដែលបដិសេធនូវកម្ម និងផលនៃកម្ម (បាបកម្មធ្ងន់) ។*
*គរុកកម្ម ជាកម្ម មានទម្ងន់ ទាំងខាងអកុសល និងខាងកុសល ៖*
*- បុគ្គលណា ប្រព្រឹត្តធ្វើទោសណាមួយ ក្នុងចំណោមទោសទាំង ៥ នៃអនន្តរិយកម្មនេះ ពេលស្លាប់ទៅ នឹងទៅកាន់ទុគតិភព ។ បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិ គឺបុគ្គលដែល*

---

[1] *ដកស្រង់ពីសៀវភៅ «**កម្ម អ្នកសាងលោកពិត** » បណ្ឌិត ម៉ែន ទីន មន សាស្ត្រាចារ្យមហាសទ្ធម្មជោតិកធជ (ប្រទេសមីយ៉ាន់ម៉ា) ។*

*បដិសេធនូវ កម្ម និងផលនៃកម្ម នោះក៏រាប់បញ្ចូលក្នុង អកុសលគរុកកម្មដែរ (បាបកម្មធ្ងន់) ។ នៅពេលដែលបុគ្គលនោះស្លាប់ទៅ នឹងទៅចាប់កំណើតក្នុងលោកន្តរិកនរក ដែលងងឹតសូន្យជានិច្ច ។*

*- ចំណែកខាងកុសលកម្មវិញ មានអំពើជាកុសលដែលប្រព្រឹត្តទៅ ក្នុង រូបភព៥ (រូបាវចរកុសលកម្ម) និង អំពើជាកុសលដែលប្រព្រឹត្តទៅ ក្នុង អរូបភព៤ (អរូបាវចរកុសលកម្ម) ដែលជាកុសលគរុកកម្ម (អំពើល្អដ៏មានទម្ងន់) ។ បុគ្គលដែលបានសម្រេចឈានរហូតដល់ថ្ងៃស្លាប់ នឹងបានទៅកើតក្នុងព្រហ្មលោក ។ បុគ្គលដែលបានចាក់ធ្លុះក្នុង មគ្គនិងផល ដោយការចម្រើននូវវិបស្សនាកម្មដ្ឋាន ហើយញុំាងកុសលកម្មក្នុងលោកុត្តរ (លោកុត្តរកុសលកម្ម) ឲ្យកើតឡើងជាគរុកកម្ម នឹងបិទនូវទ្វារ នៃអបាយទាំង៤ ជារៀងរហូត ។ ដូច្នេះបុគ្គលនោះក្រោយពេលស្លាប់ពីលោកនេះទៅ នឹងទៅកើតក្នុងសុគតិភពតែម្យ៉ាង ។*

*- ប្រសិនបើ បុគ្គលបានចម្រើនឈានឲ្យកើតឡើងហើយ ប៉ុន្តែក្រោយមកបានប្រព្រឹត្តនូវអនន្តរិយកម្មណាមួយ ក្នុងចំណោម៥ នោះ អកុសលកម្មនឹងបិទបាំងនូវកុសលកម្ម ហើយក្រោយមកញុំាងកំណើត ក្នុងអបាយឲ្យកើតឡើងបាន។ ឧទាហរណ៍ជាក់ស្តែងគឺ ភិក្ខុទេវទត្ត ដែលត្រូវជាសាច់ញាតិជីដូនមួយ នៃព្រះសម្មាសម្ពុទ្ធ បានបាត់បង់នូវឫទ្ធានុភាព ហើយទៅកើតក្នុងអវចីនរក ដោយសារតែខ្លួនបានធ្វើឲ្យមានរបួសដល់ម្រាមព្រះបាទនៃព្រះសម្ពុទ្ធ និងការដែលខ្លួនបានញុំាងគណៈសង្ឃឲ្យបែកបាក់ ។ ជាងនេះទៅទៀត ប្រសិនបើបុគ្គលណាមួយប្រព្រឹត្តនូវកម្មណាមួយក្នុងចំណោមអនន្តរិយកម្មទាំង៥ <u>បុគ្គលនោះ**នឹងមិនចាក់**ធ្លុះក្នុងលោកុត្តរធម៌ឡើយ</u> ពីព្រោះថាអកុសលកម្មនោះមានទម្ងន់ធ្ងន់ពេក។ ហេតុដូច្នេះហើយបានជាព្រះបាទ អជាតសត្តុ ខណៈពេលកំពុងតែស្តាប់នូវសាមញ្ញផលសូត្រ ដែលប្រទានដោយព្រះសម្មាសម្ពុទ្ធ ទ្រង់មានល័ក្ខណ្ឌគ្រប់គ្រាន់ដើម្បីសម្រេចសោតាបត្តិមគ្គ ប៉ុន្តែព្រះអង្គមិនបានចាក់ធ្លុះក្នុងមគ្គនិងផលឡើយ នេះក៏ព្រោះតែទ្រង់បានធ្វើឃាតព្រះបិតារបស់ទ្រង់ គឺព្រះបាទពិម្ពិសារ ។*

ក្រោយមកទៀត ថ្វីបើព្រះបាទអជាតសត្តុ បានបំពេញកុសលកម្មយ៉ាងច្រើន ដូចជាទ្រង់បានរាជូបត្ថម្ភ ក្នុងការប្រារព្ធធ្វើសង្គាយនា លើកទីមួយ និងទ្រង់បានសាងព្រះចេតិយដ៏ធំអស្ចារ្យ ដើម្បីតម្កល់ព្រះសារីរិកធាតុព្រះសាស្ដាក៏ដោយ ក៏ទ្រង់នៅតែមិនអាចគេចផុត ពីកំណើតក្នុងនរកឡើយ។ នេះគឺព្រោះតែទ្រង់បានប្រព្រឹត្តអនន្តរិយកម្ម គឺធ្វើឃាតបិតានោះឯង ។

## ២- អាសន្នកម្ម កម្មជិតពេលស្លាប់

កម្មនៅពេលជិតស្លាប់ គឺជាកម្លាំងនៃកម្ម ទាំងជាកុសលនិងអកុសលដែលបុគ្គលបានធ្វើទុកមក ឬក៏ចងចាំក្នុងរយៈពេលដ៏ខ្លីមុនពេលស្លាប់ ។ ប្រសិនបើពុំមានគរុកកម្មទេ អាសន្នកម្មនេះនឹងដើរតួនាទីរបស់ខ្លួន តាក់តែងកំណើត ដោយហេតុថាកម្មនេះមានកម្លាំងខ្លាំងក្លា ព្រោះកើតនៅពេលរៀបនឹងស្លាប់ ។

ប្រសិនបើបុគ្គលម្នាក់ដែលធ្លាប់សាងបាបកម្មច្រើន ធ្វើអំពើល្អមុនពេលខ្លួនស្លាប់ ឬក៏ចងចាំនូវអំពើល្អដែលខ្លួនបានធ្វើមុនពេលស្លាប់នោះ បុគ្គលនោះនឹងបានទៅកើតក្នុងសុគតិភព។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលម្នាក់ធ្លាប់បានសាងកុសលកម្មច្រើន តែចងចាំនូវអំពើអាក្រក់ណាមួយ ដែលខ្លួនធ្លាប់បានសាងក្នុងពេលមុន ឬក៏បានធ្វើអំពើអាក្រក់មុនពេលស្លាប់ បុគ្គលនោះនឹងទៅកើតក្នុងទុគ្គតិភព ។

ព្រោះហេតុនេះហើយ បានជាការចាំបាច់ណាស់ ចំពោះមាតាបិតា ឬមនុស្សជាទីស្រឡាញ់របស់យើង មុនពេលជិតនឹងស្លាប់ យើងធ្វើបុណ្យកុសលជូនគាត់ ឬក៏ជួយក្រើនរំលឹកពួកគាត់ ឲ្យនឹកឃើញអំពើល្អគ្រប់យ៉ាងដែលពួកគាត់បានសាង ។

ទោះបីបុគ្គលដែលបានសាងអំពើបាបច្រើន បានទៅកើតក្នុងសុគតិភព ដោយអំណាចនៃអំពើល្អដែលខ្លួនបានធ្វើមុនពេលស្លាប់ក៏ដោយ មិនមែនមានន័យថាបុគ្គលនោះ អាចគេចផុតពីអកុសលកម្ម ដែលខ្លួនបានសាងកាលនៅរស់នោះឡើយ។ នៅពេលដែលបុគ្គលនោះបានសុខចម្រើន បាបកម្មទាំងនោះក៏អាចឲ្យផល ទៅតាមការសមស្របរបស់វាដែរ ។ វៀរលែងតែបុគ្គលនោះ រក្សានូវត្រៃសិក្ខា (សីល សមាធិ បញ្ញា) ឲ្យបានខ្ជាប់ខ្ជួន ហើយបានចាក់ធ្លុះក្នុងមគ្គ និងផល ដូចនេះអកុសលកម្មទាំងឡាយនឹងមានកម្លាំង

ខ្សោយ  ហើយមិនអាចអូសទាញបុគ្គលនោះ  ទៅកាន់អបាយបានឡើយ ។

## ៣- អាចិណ្ណកម្ម  កម្មជាទម្លាប់

អាចិណ្ណកម្ម គឺជា អំពើល្អ ឬអាក្រក់ ដែលបុគ្គលទម្លាប់ធ្វើជាប្រចាំ ឬក៏អ្វីមួយដែលបុគ្គលបានធ្វើតែម្តង ហើយចងចាំនឹករលឹករឿយៗ ។

ប្រសិនបើគ្រូបង្រៀនតែងតែពន្យល់ណែនាំសិស្សរបស់ខ្លួនដោយបំណងល្អ ដើម្បីឲ្យពួកគេមានចំណេះដឹង ការបង្រៀនជាប្រចាំនេះ គឺជាកុសល អាចិណ្ណកម្ម គឺអំពើល្អជាប្រចាំ ឬ ទម្លាប់ ។  ប្រសិនបើស្រីម្នាក់តែងចំអិនអាហារ ហើយដាក់បាត្រលោកជារៀងរាល់ថ្ងៃ  ទង្វើនេះជាកុសលកម្មអចិន្ត្រៃយ៍ ។

ប្រសិនបើ បុគ្គលម្នាក់  មានប្រក្រតីរក្សានូវសីល ហើយតែងតែពិចារណាត្រេកអរ ចំពោះសេចក្តីបរិសុទ្ធ ក្នុងសីលនោះជាប្រចាំ ការរក្សានូវសីលនេះ ហៅថា កុសលអាចិណ្ណកម្ម ។ សម្រាប់បុគ្គលអ្នកចម្រើននូវកម្មដ្ឋាន  ការចម្រើននូវកម្មដ្ឋាននេះ ហៅថាអាចិណ្ណកម្ម ។ សម្រាប់បុគ្គលអ្នកនេសាទត្រី  បរបាញ់សត្វ  លួចឆក់ប្លន់ ។ល។  ដើម្បីការចិញ្ចឹមជីវិតជាប្រចាំ ។ ទង្វើបាបទាំងនេះ ជាអកុសលអាចិណ្ណកម្ម  គឺអំពើអាក្រក់ជាប្រចាំ ឬទម្លាប់ ។

ប្រសិនបើ មិនមានវត្តមានគរុកកម្ម និងអាសន្នកម្មទេ អាចិណ្ណកម្មនឹងដើរតួនាទីរបស់វាជាអ្នកសម្រេចតាក់តែងជាតិកំណើតថ្មី ។

## ៤- កដត្តាកម្ម  កម្មមិនជាក់លាក់

កដត្តាកម្មនេះ គឺជាកម្មទីទៃអំពីកម្មទាំងឡាយដែលបានរៀបរាប់មកខាងលើ  គឺជាកម្មដែលបុគ្គលបានសាងពីមុនមក ហើយមិនបានចងចាំទេ  ប៉ុន្តែវាអាចមានកម្លាំងគ្រប់គ្រាន់ ដើម្បីតាក់តែងជាតិកំណើតថ្មីបានដែរ ។ កម្មមិនជាក់លាក់នេះ វានឹងមានឱកាសតាក់តែងកំណើតថ្មីបាន  ប្រសិនបើមិនមានវត្តមាននៃកម្មទាំងបីខាងលើនោះ មកបំពេញតួនាទីទេ ។

មាន កុសលកម្ម និង អកុសលកម្ម រាប់មិនអស់នៅក្នុងសន្តានដែលបានសន្សំទុកមក ហើយទាំងអស់នេះសុទ្ធតែអាចដើរតួជា កដត្តាកម្មបានទាំងអស់។ ប្រសិនបើកុសលកដត្តាកម្ម (អំពើល្អមិនច្បាស់លាស់) មានឱកាសឲ្យផល បុគ្គលនោះនឹងមានសំណាងល្អ ។ តែបើ អកុសលកដត្តាកម្មឲ្យផលមុននោះ នឹងមានដំណើរឆ្ពោះទៅកាន់ទុគ្គតិភព ហើយបើទៅកើតក្នុងទីនោះហើយ ពិបាកនឹងចេញមកវិញណាស់ ព្រោះទីនោះមិនមែនជាកន្លែង កសាងធ្វើបុណ្យទាន ។ យើងមិនគួរអនុញ្ញាតឲ្យ អកុសលកដត្តាកម្ម សម្រេចជោគវាសនាឲ្យយើងទេ ព្រោះថា យើងជាម្ចាស់ជោគវាសនារបស់ខ្លួនយើង ។ ដូច្នេះយើងគួរណាស់តែព្យាយាមទម្លាប់ធ្វើអំពើល្អឲ្យបានច្រើន ដើម្បីឲ្យអំពើល្អនេះតាក់តែងកំណើតថ្មី ក្នុងសុគតិភពឲ្យយើង ។

សេចក្តីបន្ថែម

**មរណៈ** គឺសេចក្តីស្លាប់ មានបួនយ៉ាង គឺ

១- មរណៈដោយអស់អាយុ គឺស្លាប់ដោយជំងឺ ដោយជរា។ កាលពីសម័យព្រះពុទ្ធ មនុស្សអាយុ ១០០ឆ្នាំ ។ ព្រះពុទ្ធនៃយើងព្រះអង្គបានព្រះជន្មតែ ៨០ ឆ្នាំក៏បរិនិព្វានទៅ ។ មកដល់យើងសព្វថ្ងៃនេះ គឺ ជាង ២៥០០ ឆ្នាំហើយ ដែលព្រះពុទ្ធបរិនិព្វាន ដូច្នេះអាយុយើងត្រូវថយអស់ ២៥ ឆ្នាំ[2] គឺ មនុស្ស អាយុច្រើនជាង (១០០ - ២៥) = ៧៥ ឆ្នាំ មានមិនច្រើនទេ ។ ចំពោះមនុស្សដែលមានអាយុលើសពី ៧៥ឆ្នាំទៅ គឺ បានដោយសារបុណ្យ ។

២- មរណៈដោយអស់បុណ្យ។ ដូចទេវតា ដែលអស់បុណ្យ ក៏ស្លាប់ ហើយមកចាប់ជាតិជាមនុស្ស ឬ ទៅ អបាយ ក៏មាន ។

[2] ពីព្រោះតាមជំនឿ ខាងព្រះពុទ្ធសាសនា ក្នុង ១០០ឆ្នាំ អាយុមនុស្សត្រូវថយអស់ ១ ឆ្នាំ ដូច្នេះ ក្នុង រយៈពេល ២៥០០ ឆ្នាំ (នៅព.ស ២៥៦១ នេះ) អាយុមនុស្សយើងត្រូវថយអស់ ២៥ ឆ្នាំ ។

៣- មរណៈដោយអស់អាយុ និង អស់បុណ្យ  ទាំង២ ចុះព្រមគ្នា ។ ឧបមា ដូចចង្កៀង ប្រេងកាត ដែលរលត់ ដោយអស់ទាំងប្រេង អស់ទាំងប្រឆេះ ដោយព្រមគ្នា។

៤- មរណៈដោយកម្មចាស់ចូលទៅកាត់បង់ ។ គឺស្លាប់ដោយ កម្មដែលបានធ្វើពីកាលមុន មកកាត់ផ្តាច់ជីវិត ។

<u>មនុស្ស ជិតនឹងស្លាប់ ជួនកាលមានអារម្មណ៍</u> ៖

១- **កម្ម** គឺកុសល ឬអកុសល ដែលនឹងឲ្យបដិសន្ធិ ក្នុងភពខាងមុខ មកប្រាកដ ជាអារម្មណ៍។ កម្មជាកុសលនោះ ដូចជាខ្លួនធ្លាប់ ឲ្យទាន រក្សាសីល  ស្តាប់ធម៌  ឬ ចំរើនភាវនា ធ្លាប់ធ្វើយ៉ាងណា ក៏មកប្រាកដ<u>ដូចកំពុងធ្វើយ៉ាងនោះ</u> ។  ចំណែកខាង អកុសលវិញ ដូចជា ខ្លួនធ្លាប់សម្លាប់សត្វ លួចទ្រព្យ ឆបោក បំបាត់ ឬវាយដំ សំពង ចងសត្វទាំងពួងយ៉ាងណា   ក៏មកប្រាកដ<u>ដូចកំពុងធ្វើយ៉ាងនោះ</u> ។

២- **កម្មនិមិត្ត** គឺ វត្ថុដែលជាគ្រឿងធ្វើកុសល ឬអកុសល ។ មានរូបជាដើមដែលខ្លួនធ្លាប់ បាន កាលវេលាធ្វើកម្មជាកុសល ឬ អកុសលនោះ ។ គ្រឿងដែលមកប្រាកដក្នុង អារម្មណ៍  ដូចជា គ្រឿងដែលធ្វើកុសលក្នុងបច្ចុប្បន្នជាតិនេះមាន សម្ពត់ និងគ្រឿង សក្ការៈផ្សេងៗជាដើម  ។  កម្មនិមិត្ត ចំណែកអកុសល គឺនឹងឃើញគ្រឿងដែលបៀតបៀន សត្វផ្សេងៗ  ដែលខ្លួនធ្លាប់យកទៅធ្វើក្នុងជាតិនេះ  មាន ដាវ លំពែង មង  ជាដើម ។

៣- **គតិនិមិត្ត** គឺ  គ្រឿងបរិភោគដែលខ្លួននឹងគប្បីបានក្នុងភពដែលនឹងទៅកើតជា លំដាប់  មកប្រាកដជាអារម្មណ៍ ។ គតិនិមិត្ត មាន ២ យ៉ាង គឺ សុគតិ ១   ទុគ្គតិ១  ។

**សុគតិ**  គឺ ដំណើរដែលនឹងទៅល្អនោះ   គឺនឹងឃើញ  វិមានប្រាសាទ  ទិព្វសម្បត្តិ  និង នាងទេពអប្សរជាដើម។  សុទ្ធតែជាចំណែកដែលល្អ ។

**ទុគ្គតិ**  គឺដំណើរដែលនឹងទៅសោយទុក្ខនោះ  គឺ នឹងឃើញអណ្តាតភ្លើងនាយនិរយបាល ឆ្កែ  ឬ ត្មាត ជាដើម   ដែលនឹងមកបៀតបៀនខ្លួន ។

*កម្មដែលនឹងមកប្រាកដនោះ គឺមកប្រាកដក្នុងមនោទ្វារ ។ កម្មនោះប្រាថ្នាយក កម្ម ជា អតីត* ដែលខ្លួនបានធ្វើហើយយ៉ាងណា ក៏ឃើញដូចកំពុងធ្វើយ៉ាងនោះ ។

*អារម្មណ៍មួយដែលខ្ញុំយល់ថាគួរនឹកដែរ គឺ* **គុណព្រះពុទ្ធ** *ពីព្រោះយើងបានយក* **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ** *ជាទីពឹង ទីរលឹក។*

*ព្រះពុទ្ធមុននឹងបរិនិព្វាន បានគិតមកទុក្ខនៃសត្វលោក ហើយបណ្តាំចុងក្រោយរបស់ ព្រះអង្គនៅក្នុងគម្ពីរព្រះត្រៃបិដកខ្មែរ ភាគទី ១៦ ទំព័រ ២៩៧* មានដូចតទៅនេះ ៖

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់ នឹងល្អ ចូររក្សាចិត្តរបស់ខ្លួន ឲ្យរឿយៗចុះ ។

ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម៌វិន័យនេះ (ភិក្ខុនោះ) នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវ ព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខ បានមិនខាន ។